## បញ្ជីឆែកមើលផ្នែកសោតវិញ្ញាណ និងការនិយាយសំរាប់

### ពីកំណើត ទៅ៣ខែ

- ☐ អាចចាប់សម្លេង ឬស្គាល់សូរសំឡេងដែលធ្លាប់ឮ
- ☐ ភ្ញាក់ផ្អើលដោយសារ ឬលោតពេលណាឮសូរសម្លេងភ្លាម

### ពី៣ខែ ទៅ៦ខែ

- ☐ ងាកក្បាល ឬក្រឡេកភ្នែកឆ្ពោះទៅរកសូរសម្លេងដែលធ្វើឲ្យចាប់អារម្មណ៍
- ☐ ហាក់បីដូចជាចេះស្តាប់
- ☐ ភ្ញាក់ពីដេកយ៉ាងងាយនៅពេលឮសូរសម្លេង
- ☐ ចាប់ផ្តើម បញ្ចេញសម្លេងដូចជាពាក្យសម្តី

### ពី៦ខែ ទៅ១២ខែ

- ☐ ឆាប់យល់ពាក្យដែលងាយស្រួលដូចជា 'no' និង 'bye-bye'
- ☐ ចាប់ផ្តើមធ្វើត្រាប់តាមសម្លេង
- ☐ ងាកក្បាលទៅរកសម្លេងស្រាលៗ

### ពី១២ខែ ទៅ១៨ខែ

- ☐ ហាក់បីដូចជាយល់ពាក្យកាន់តែច្រើនក្នុងមួយអាទិត្យៗ
- ☐ ពេលណាសួរ ចេះចង្អុលទៅរកមនុស្ស ផ្នែកនៃខ្លួនប្រាណ ឬប្រដាប់ក្មេងលេង
- ☐ ធ្វើតាមពាក្យដែលនិយាយណែនាំ ដូចជាពាក្យ "អង្គុយចុះ"

ប្រសិនបើលោកអ្នកមានកង្វល់អំពីសោតវិញ្ញាណរបស់ទារកលោកអ្នក សូមទាក់ទងជាមួយវេជ្ជបណ្ឌិតទារករបស់លោកអ្នក ឬបុគ្គលិកនៅមន្ទីរព្យាបាលប្រចាំតំបន់របស់លោកអ្នក។



**កម្មវិធីផ្នែកសុខភាពសោតវិញ្ញាណ** មានគោលបំណងរកឲ្យឃើញនូវទារកទើបនឹងកើតដែលបានខូចបង់ផ្នែកសោតវិញ្ញាណជាអចិន្ត្រៃយ៍។ កម្មវិធីនេះនឹងផ្តល់ជូនដោយឥតគិតថ្លៃ ហើយនៅជិតបំណាច់ឆ្នាំ២០០៦ កម្មវិធីនេះនឹងមានសំរាប់ទារកទើបនឹងកើតទាំងអស់នៅរដ្ឋឃ្វីនស្លែន។

Queensland Government
Queensland Health





# ការពិនិត្យមើលសោតវិញ្ញាណទារករបស់លោកអ្នកដោយឥតគិតថ្លៃ

Queensland Government
Queensland Health

# ការពិនិត្យមើលសោតវិញ្ញាណរបស់ទារកលោកអ្នក

សុខភាពផ្នែកសោតវិញ្ញាណមានសារសំខាន់លើការធំលូតលាស់ខាងការនិយាយ និងខាងភាសាកូនរបស់លោកអ្នកក្នុងពេលច្រើនខែដំបូងនៃជីវិត។ មានទារកប្រហែល១នាក់ ឬ២នាក់ក្នុងចំណោមទារក១០០០នាក់នឹងត្រូវខូចបង់សោតវិញ្ញាណយ៉ាងធ្ងន់ធ្ងរ។

ប្រសិនបើគេមិនបានរកឃើញការខូចបង់សោតវិញ្ញាណនេះ នៅក្នុងរយៈពេលដំបូងទេ វាអាចធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់ផ្នែកនិយាយ និងខាងភាសាព្រមទាំងការរៀនសូត្រនៅសាលារៀនទៅអនាគត។

## ផ្នែកពិនិត្យសុខភាពរបស់ទារក

កម្មវិធីផ្នែកសុខភាពសោតវិញ្ញាណ មានគោលបំណងរកឲ្យឃើញនូវទារកទើបនឹងកើតដែលបានខូចបង់ផ្នែកសោតវិញ្ញាណជាអចិន្ត្រៃយ៍។ កម្មវិធីនេះនឹងផ្ដល់ជូនដោយឥតគិតថ្លៃ ហើយនៅជិតបំណាច់ឆ្នាំ២០០៦ កម្មវិធីនេះនឹងមានសំរាប់ទារកទើបនឹងកើតទាំងអស់នៅក្នុងរដ្ឋឃ្វីនស្លែន។

ទារករបស់លោកអ្នកនឹងបានទទួលការពិនិត្យមើលសុខភាពមួយចំនួន បន្ទាប់ពីគេកើតមក។ ការពិនិត្យមើលមួយក្នុងចំណោមការពិនិត្យទាំងនេះ គឺការពិនិត្យរកមើលសោតវិញ្ញាណដែលខូចបង់។ ការពិនិត្យមើលនេះត្រូវធ្វើឲ្យបានយ៉ាងឆាប់ដែលអាចធ្វើទៅបានបន្ទាប់ពីកើតមក។ ប្រសិនបើការពិនិត្យមើលនេះមិនបានធ្វើមុនពេលដែលលោកអ្នក និងទារករបស់លោកអ្នកចាកចេញពីមន្ទីរពេទ្យទេ ទារករបស់លោកអ្នកនៅតែអាចទទួលការពិនិត្យមើលនេះបានក្នុងភាពជាអ្នកជម្ងឺក្រៅមន្ទីរពេទ្យ ភ្លាមៗបន្ទាប់ពីលោកអ្នកត្រឡប់មកផ្ទះវិញ។

## តើការពិនិត្យមើលនេះត្រូវធ្វើឡើងដោយបែបណា?

ការពិនិត្យមើលសោតវិញ្ញាណ ពុំធ្វើឲ្យទារករបស់លោកអ្នកមានការឈឺចាប់ទេ។ គិលានុបដ្ឋាក ឬអ្នកបានទទួលការហ្វឹកហ្វឺនផ្នែកពិនិត្យសោតវិញ្ញាណម្នាក់នឹងធ្វើការពិនិត្យមើលក្នុងពេលទារករបស់លោកអ្នកនៅស្ងៀម ឬដេកលក់។ គេនឹងដាក់ទ្រនាប់តូចៗមួយចំនួនយ៉ាងថ្នមៗនៅជុំវិញក្បាលទារករបស់លោកអ្នក និងឧបករណ៍សំរាប់ពាក់ស្ដាប់នឹងដាក់ដោយថើៗនៅលើត្រចៀកទាំងសងខាង។ សម្លេងក្ញឹកយ៉ាងស្រាលនឹងដាក់ឲ្យឮក្នុងត្រចៀកទារករបស់លោកអ្នក។ ទ្រនាប់ទាំងនេះនឹងកត់ត្រានូវការឆ្លើយតបរបស់ទារកលោកអ្នកទៅនឹងសូរសម្លេងទាំងនោះ។

## តើពេលណាទើបខ្ញុំបានដឹងពីលទ្ធផល?

លទ្ធផលនៃការពិនិត្យមើលនឹងត្រូវដឹងភ្លាមៗ ហើយនឹងត្រូវកត់ចុះនៅក្នុងកំណត់ត្រាសុខភាពផ្ទាល់របស់ទារកលោកអ្នក។ អ្នកធ្វើការពិនិត្យមើល នឹងពិភាក្សាអំពីលទ្ធផលនេះជាមួយលោកអ្នក។ សូមសួរសំនួរប្រសិនបើមានចង្ងល់ណាមួយដែលលោកអ្នកពុំយល់ច្បាស់។

## តើយើងនឹងទទួលបានព័ត៌មានអ្វីខ្លះពីការពិនិត្យមើលនេះ?

ចំពោះត្រចៀកនីមួយៗ ការពិនិត្យមើលនឹងឲ្យលទ្ធផល "ជាប់" ឬ "បញ្ជូន"។ ការពិនិត្យមើលនេះនឹងពុំផ្ដល់ព័ត៌មានលំអិតអំពីសោតវិញ្ញាណរបស់ទារកលោកអ្នកឡើយ។

## តើលទ្ធផល "ជាប់ "មានន័យដូចម្ដេច?

លទ្ធផល "ជាប់" ចំពោះត្រចៀកទាំងពីរបញ្ជាក់ថាទារករបស់លោកអ្នកមិនទំនងជាមានការខូចបង់សោតវិញ្ញាណដែលអាចប៉ះពាល់ដល់ការផ្នែកការនិយាយ និងភាសារបស់គេទេ។

ទារកមួយចំនួនតូចអាចជាប់ការពិនិត្យមើល ក៏ប៉ុន្តែមានកត្តាមួយចំនួនដែលគេធ្លាប់ស្គាល់អំពីប្រភេទសោតវិញ្ញាណខូចបង់ដែលត្រូវប្រើពេលយូរមុនលេចចេញឲ្យឃើញ។ ប្រសិនបើស្ថិតនៅក្នុងករណីនេះ ទារករបស់លោកអ្នកនឹងបានទទួលនូវការធ្វើតេស្តសោតវិញ្ញាណពីអ្នកឯកទេសផ្នែកសោតវិញ្ញាណនៅពេលណាមួយ មុនដល់ថ្ងៃខួបកំណើត១ឆ្នាំរបស់គេ។ ពេលវេលាសំរាប់ការធ្វើតេស្តនេះ អាស្រ័យទៅលើសេចក្ដីត្រូវការជាក់លាក់ណាមួយរបស់កូនលោកអ្នក។ ក្នុងខណៈពេលដែលមានទារកមួយចំនួនតូចប៉ុណ្ណោះដែលមានកត្តាប្រឈម មុខនឹងគ្រោះថ្នាក់ទាំងនេះកើតឡើង ហើយមានការខូចបង់សោតវិញ្ញាណ នោះគឺជាការសំខាន់ដែលត្រូវធ្វើឲ្យបាកដថា ទារករបស់លោកអ្នកបានទទួលការធ្វើតេស្តនេះ។

សូមចាំថាសោតវិញ្ញាណរបស់ទារក និងកូនក្មេងអាចផ្លាស់ប្ដូរក្នុងអម្លុងពេលណាមួយ។ ប្រសិនបើពេលណាមួយលោកអ្នកមានកង្វល់អំពីសោតវិញ្ញាណរបស់ទារក ឬកូនរបស់លោកអ្នកសូមទាក់ទងវេជ្ជបណ្ឌិត ឬបុគ្គលិកនៅមន្ទីរព្យាបាលប្រចាំតំបន់របស់លោកអ្នក។ ការធ្វើតេស្តសោតវិញ្ញាណអាចធ្វើបានចំពោះទារក ឬកូនក្មេងអាយុប៉ុន្មានក៏បាន។

## ការណាត់ជួបដើម្បីពិនិត្យមើលសោតវិញ្ញាណសំរាប់

..................................................................

ថ្ងៃខែឆ្នាំ ..........................................................

ពេលម៉ោង ....................................................

ទីកន្លែង ........................................................

## តើលទ្ធផល "បញ្ជូន៍ មានន័យដូចម្ដេច?

លទ្ធផល "បញ្ជូន" ក្នុងការពិនិត្យមើលសោតវិញ្ញាណអាចបណ្ដាលមកពីមូលហេតុមួយចំនួន:

- ទារករបស់លោកអ្នកនៅមិនស្ងៀមក្នុងអម្លុងពេលពិនិត្យមើល។
- ប្រហែលជាមានសូរសម្លេងពីខាងក្រៅផ្សេងទៀតក្នុងអម្លុងពេលពិនិត្យមើល។
- ទារករបស់លោកអ្នកប្រហែលមានវត្ថុរាវ ឬការរាំងស្ទះបណ្ដោះអាសន្នណាមួយក្នុងត្រចៀកបន្ទាប់ពីបានកើតមក
- ទារកមួយចំនួនតូចអាចនឹងខូចបង់សោតវិញ្ញាណបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍។ កំរិតនៃការខូចបង់អាចមានចាប់ពីកំរិតល្មម ទៅធ្ងន់ធ្ងរ។

ប្រសិនបើការពិនិត្យមើលសោតវិញ្ញាណលើកទី១របស់ទារកលោកអ្នកបង្ហាញឲ្យឃើញលទ្ធផល "បញ្ជូន" ចំពោះត្រចៀកម្ខាង ឬទាំងសងខាង នោះការពិនិត្យមើលសោតវិញ្ញាណលើកទី២នឹងត្រូវធ្វើឡើងចំពោះត្រចៀកទាំងសងខាង។

ប្រសិនបើការពិនិត្យមើលសោតវិញ្ញាណលើកទី២របស់ទារកលោកអ្នកបង្ហាញឲ្យឃើញលទ្ធផល "បញ្ជូន" ចំពោះត្រចៀកម្ខាង ឬទាំងសងខាងនោះលោកអ្នកនឹងបានទទួលនូវការធ្វើតេស្តពីអ្នកឯកទេសផ្នែកសោតវិញ្ញាណ ហើយលោកអ្នកនឹងបានទទួលនូវកូនសៀវភៅមួយច្បាប់បន្ថែម ដលពន្យល់ប្រាប់អំពីកិច្ចការនោះលំអិតថែមទៀត។

## តើខ្ញុំអាចទទួលព័ត៌មានបន្ថែមទៀតពីកន្លែងណា?

ប្រសិនបើលោកអ្នកចង់បានព័ត៌មានបន្ថែមទៀតអំពីការពិនិត្យមើលសោតវិញ្ញាណទារករបស់លោកអ្នក សូមទាក់ទងជាមួយមន្ទីរពេទ្យប្រចាំតំបន់របស់លោកអ្នក វេជ្ជបណ្ឌិតរបស់ទារកលោកអ្នក ឬបុគ្គលិកនៅមន្ទីរព្យាបាលប្រចាំតំបន់របស់លោកអ្នក។







LAST UPDATED: February 2006

Language: Khmer